# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**នាយកដ្ឋានគយនិងរដ្ឋាករ**

លេខ: ៩៨៧ គ.រ

*រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០០៥*

## សេចក្តីណែនាំ
## ស្តីពី
## បែបបទគ្រប់គ្រងលិខិតអនុញ្ញាតដឹកជញ្ជូនទំនិញនាំចូល

✽

ដោយអនុលោមតាមច្បាប់ស្តីពីពន្ធលើទំនិញនាំចេញ នាំចូលជាធរមាន ព្រមទាំងដើម្បីលើកកំពស់នៃការទទួលខុសត្រូវឱ្យបានច្បាស់លាស់ក្នុងការគ្រប់គ្រងចែកចាយ ការចេញ ការប្រើប្រាស់ និងការត្រួតពិនិត្យលិខិតអនុញ្ញាតដឹកជញ្ជូនទំនិញនាំចូលក្រោយពេលបញ្ចេញទំនិញពីគយ ខ្ញុំសូមធ្វើការណែនាំដល់គ្រប់សាខា ការិយាល័យ និងទីស្នាក់ការគយនិងរដ្ឋាករទាំងអស់ដូចខាងក្រោម ÷

១- ត្រូវចាត់តាំងប្រគល់ភារកិច្ចឱ្យបានច្បាស់លាស់ជាលាយលក្ខអក្សរ នូវមន្ត្រីគយនិងរដ្ឋាករក្នុងចំនួនសមស្របតាមការងារជាក់ស្តែងនៃមូលដ្ឋានគយនិងរដ្ឋាករនីមួយៗ ដើម្បីឱ្យទទួលខុសត្រូវគ្រប់គ្រងការចេញ និងរក្សាឯកសារលិខិតអនុញ្ញាតដឹកជញ្ជូនទំនិញនាពេលអនុញ្ញាតឱ្យបញ្ចេញទំនិញពីគយ។ ក្នុងករណីមានតម្រូវការចេញលិខិតអនុញ្ញាតដឹកជញ្ជូនតិចតួច ពុំតម្រូវឱ្យការចាត់តាំងមន្ត្រីដោយឡែកសំរាប់ការគ្រប់គ្រងលិខិតអនុញ្ញាតដឹកជញ្ជូនដូចនេះទេ ហើយថ្នាក់ដឹកនាំអង្គភាពគយនិងរដ្ឋាករពាក់ព័ន្ធត្រូវគ្រប់គ្រងការងារនេះដោយផ្ទាល់តែម្តង។ បញ្ជីរាយនាម និងគំរូហត្ថលេខាអ្នកទទួលខុសត្រូវក្នុងការគ្រប់គ្រង ចេញលិខិតអនុញ្ញាតដឹកជញ្ជូន ត្រូវបញ្ជូនជាបន្ទាន់ដោយសាខា ការិយាល័យ និងទីស្នាក់ការគយនិងរដ្ឋាករពាក់ព័ន្ធមកតំកល់ទុកនៅទីចាត់ការគយនិងរដ្ឋាករ (ការិយាល័យរដ្ឋបាល- បុគ្គលិក) រៀងរាល់ដំណាច់ឆ្នាំនីមួយៗ ឬរាល់ពេលមានការផ្លាស់ប្តូរភារកិច្ចនេះ ដើម្បីចងក្រងជាឯកសាររួមមួយ បំរើឱ្យប្រព័ន្ធត្រួតពិនិត្យគយជាបន្តបន្ទាប់។

២- លិខិតអនុញ្ញាតដឹកជញ្ជូន ត្រូវចេញជូនចំពោះតែទំនិញនាំចូលដែលបានបំពេញបែបបទគយចប់សព្វគ្រប់ ហើយពុំអាចដឹកជញ្ជូនទាំងស្រុងក្នុងមធ្យោបាយដឹកជញ្ជូនតែមួយ ដោយហេតុថា មានបរិមាណច្រើន ឬហេតុផលសមស្របផ្សេងទៀតប៉ុណ្ណោះ។ លិខិតនេះ ច្បាប់ដើមត្រូវអមភ្ជាប់ជាមួយបង្កាន់ដៃពន្ធច្បាប់ចំលងដែលមានបញ្ជាក់ពីការកាត់ស្តុកច្បាស់លាស់ ហើយត្រូវកាន់ជាប់ជាមួយមធ្យោបាយដឹកជញ្ជូនដែលមានបញ្ជាក់អត្តសញ្ញាណកម្មច្បាស់លាស់ក្នុងលិខិតនេះ។ ចំពោះទំនិញដែលអាចដឹកក្នុង



អាស័យដ្ឋាន: លេខ ៦-៨ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទ / ទូរសារ (៨៥៥-២៣) ២១៤ ០៦៥ / ៧២៥ ១៤៧ / ២១២ ៨៤៧ E-mail: customs@camnet.com.kh

មធ្យោបាយតែមួយ ពុំគួរឱ្យចេញលិខិតអនុញ្ញាតដឹកជញ្ជូនឡើយ គឺត្រូវប្រើប្រាស់បង្កាន់ដៃពន្ធច្បាប់ដើមអមទំនិញនោះជាការស្រេច។

៣- លិខិតអនុញ្ញាតដឹកជញ្ជូនមួយច្បាប់ ត្រូវចេញជូនសំរាប់ទំនិញមិនលើសមួយមធ្យោបាយដឹកជញ្ជូន។ មិនអនុញ្ញាតឱ្យចេញលិខិតអនុញ្ញាតដឹកជញ្ជូនតែមួយសំរាប់ទំនិញដែលផ្ទុកក្នុងមធ្យោបាយដឹកជញ្ជូនច្រើនឡើយ។

៤- ត្រូវកាន់កាប់ ថែរក្សាគល់បញ្ជី ឬឯកសារគំកល់នានាពាក់ព័ន្ធនឹងការគ្រប់គ្រងចេញលិខិតអនុញ្ញាតដឹកជញ្ជូននេះឱ្យមានសុវត្ថិភាពត្រឹមត្រូវ ដើម្បីបំរើឱ្យការត្រួតពិនិត្យ ផ្ទៀងផ្ទាត់នានាក្នុងករណីចាំបាច់។

៥- លិខិតអនុញ្ញាតដឹកជញ្ជូន អមមធ្យោបាយដឹកជញ្ជូនដូចរៀបរាប់ខាងលើ ត្រូវមានការបញ្ជាក់ "បានឃើញឆ្លងកាត់" ពីអង្គភាពគយនិងរដ្ឋាករមួយចំនួនតាមគំរាយផ្លូវដែលត្រូវដឹកជញ្ជូនទំនិញតាមការកំណត់ដោយខ្សែករបស់ទីចាត់ការគយនិងរដ្ឋាករ។

៦- លិខិតអនុញ្ញាតដឹកជញ្ជូនទំនិញ ត្រូវចេញជូនតែមធ្យោបាយដឹកជញ្ជូនណាដែលស្របច្បាប់ បានន័យថា បានបំពេញកាតព្វកិច្ចពន្ធត្រឹមត្រូវ មានផ្លាកលេខសំគាល់មធ្យោបាយដឹកជញ្ជូនច្បាស់លាស់ជាប់នឹងរថយន្ត ដែលចេញដោយក្រសួងសាធារណការ និងដឹកជញ្ជូន ឬផ្លាកសំគាល់របស់ទីចាត់ការគយនិងរដ្ឋាករ។ ក្នុងករណីចាំបាច់ផ្សេងពីនេះ ត្រូវមានការអនុញ្ញាតជាមុនពីទីចាត់ការគយនិងរដ្ឋាករ។

៧- ត្រូវធ្វើការណែនាំជាបន្ទាន់ដល់អ្នកបំពេញបែបបទគយ ក៏ដូចជាអាជីវករវិស័យដឹកជញ្ជូននានា ពីខ្លឹមសារនៃសេចក្តីណែនាំនេះឱ្យបានជ្រួតជ្រាប និងអនុវត្តបានទាន់ពេលវេលា។

ទទួលបានសេចក្តីណែនាំនេះ សូមអស់លោក លោកស្រី ដែលជាប្រធានសាខា ការិយាល័យ និងទីស្នាក់ការគយនិងរដ្ឋាករទាំងអស់ ចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៦ តទៅ ។

ប្រតិភូរាជរដ្ឋាភិបាល

ទទួលបន្ទុកជាអគ្គនាយកទីចាត់ការគយនិងរដ្ឋាករ

បណ្ឌិត.ប៉ែន_ស៊ីម៉ន

**ចម្លងជូន :**

- ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី កសហវ
  "ជូនជ្រាបជាពតិមាន"
- គ្រប់សាខា ការិយាល័យ និងទីស្នាក់ការគយនិងរដ្ឋាករ
- គ្រប់សភាពាណិជ្ជកម្ម ខេត្ត ក្រុង
  "ដើម្បីសុំកិច្ចសហការផ្សព្វផ្សាយ និងអនុវត្ត"
- ឯកសារ- កាលប្បវត្តិ